**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខៈ៨៩
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០
សាលក្រមលេខ៖១០៥(ខ)
ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ នៅថ្ងៃទី២០ខែមករាឆ្នាំ២០២១វេលាម៉ោង០២និង៣០នាទីរសៀល លើសំណុំរឿងរដ្ឋប្បវេណីលេខ៨៩ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពចូលរួមដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

**លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

**ក្រឡាបញ្ជី**

**លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ**

**ដើមចោទឈ្មោះ** [redacted] គីមហុក ភេទប្រុស អាយុ៤៥ឆ្នាំ មុខរបរលក់ដូរ [redacted] ឪពុកឈ្មោះ [redacted] សៀកឡេង (ស្លាប់) ម្តាយឈ្មោះ [redacted] ចែអ៊ីម (រស់) ប្រពន្ធឈ្មោះ [redacted] សម្ផស្ស មានកូន០១នាក់។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ឈ្មោះ [redacted] គីមហុក

**ចុងចម្លើយឈ្មោះ** [redacted] សម្ផស្ស ភេទស្រី អាយុ៤០ឆ្នាំ មុខរបរបុគ្គលិកកាកបាតក្រហម អាសយដ្ឋានផ្ទះ [redacted] ឪពុកឈ្មោះ [redacted] សារុន(ស្លាប់) ម្តាយឈ្មោះ [redacted] សារ៉ាន់ (រស់) ប្តីឈ្មោះ [redacted] គីមហុក មានកូន០១នាក់។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ឈ្មោះ [redacted] សម្ផស្ស

## I.អង្គហេតុនិងចំណុចវិវាទ

### ក.ការទាមទាររបស់អ្នកប្តឹងសុំ:

១- ប្តឹងសុំលែងលះពីឈ្មោះ [redacted] សម្ផស្ស ភេទស្រី កើតនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨០។

២- សុំសិទ្ធិអំណាចមេបាលើកូនស្រីចំនួន០១នាក់ឈ្មោះ [redacted] សុខហេង កើតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣។

### ខ.ការពន្យល់គ្រួសៗអំពីដំណើររឿងក្តី:

ដើមចោទលោក [redacted] គីមហុក និងចុងចម្លើយឈ្មោះ [redacted] សម្ផស្ស បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រឹមត្រូវតាមច្បាប់នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ការរស់នៅជាមួយគ្នាមានកូន០១នាក់ឈ្មោះ [redacted] **សុខហេង** ភេទស្រី កើតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣។ ការរស់នៅរវាងដើមចោទនិងចុងចម្លើយមិនចុះសំរុងនិងគ្នាជាហេតុធ្វើឱ្យដើមចោទនិងចុងចម្លើយអស់មនោសញ្ចេតនានឹងគ្នា។ ដើមចោទ និងចុងចម្លើយសុំអំណាចមេបាលើកូនឈ្មោះ [redacted] សុខហេង ភេទស្រី កើតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ ដូចគ្នា។ ប្រាក់ប្រដាប់ក្តីដើមចោទជាអ្នកទទួលបន្ទុក។

**គ.អង្គហេតុដែលអះអាងដោយគូភាគី:**

**១.ការអះអាងរបស់ដើមចោទ**

**-ដើមចោទឈ្មោះ** [redacted] **គីមហុក** បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំនិងចុងចម្លើយអ្នកស្រី [redacted] **សម្ផស្ស** បានអាពាហ៍ពិពាហ៍និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ អំឡុងពេលរស់នៅជាមួយគ្នាមានកូន០១នាក់ ឈ្មោះ [redacted] **សុខហេង** កើតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ ។ ការរស់នៅក្នុងរង្វង់ក្រុមគ្រួសារគឺមិនចុះសំរុងនិងគ្នា ហេតុនេះខ្ញុំបាទអស់មនោសញ្ចេតនាពីចុងចម្លើយទៀតហើយ។

កូន០១នាក់ឈ្មោះ [redacted] **សុខហេង** កើតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ ខ្ញុំសុំសិទ្ធិអំណាចមេបា ដោយសារខ្ញុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងកូនឲ្យមានការសិក្សាអប់រំ មានអនាគតល្អប្រសើរទៅថ្ងៃខាងមុខ និងឲ្យចុងចម្លើយបង់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព។ ទ្រព្យសម្បត្តិរួម និងបំណុលរួមគ្មាន។

ប្រាក់ប្រដាប់ក្តីតុលាការខ្ញុំជាអ្នកទទួលបន្ទុក។

**២.ការអះអាងរបស់ចុងចម្លើយ**

-**ចុងចម្លើយឈ្មោះ** [redacted] **សម្ផស្ស** បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំឯកភាពក្នុងការលែងលះជាមួយ ដើមចោទឈ្មោះ [redacted] **គីមហុក** ដោយហេតុថាខ្ញុំនិងដើមចោទបានអស់មនោសញ្ចេតនាពីគ្នាហើយ។ កូន០១នាក់ឈ្មោះ [redacted] **សុខហេង** កើតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ ខ្ញុំសុំមានសិទ្ធិអំណាចមេបា ដោយហេតុថា ប្តីខ្ញុំឈ្មោះ [redacted] **គីមហុក** មានសុខភាពមិនសូវល្អ ហើយគាត់រារាំងមិនឲ្យខ្ញុំទៅជួបកូនខ្ញុំឡើយដោយចាក់សោរ និងប្រើពាក្យគំរាមកំហែងមិនឲ្យមកតាមខ្ញុំ ដោយខ្ញុំទៅរកខ្ញុំដល់កន្លែងធ្វើការដោយជិះកងទៅ និងឲ្យដើមចោទបង់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព។ ទ្រព្យសម្បត្តិរួម និងបំណុលរួមគ្មាន។ ប្រាក់ប្រដាប់ក្តីតុលាការលោក [redacted] **គីមហុក** ជាអ្នកទទួលបន្ទុក។

**៣.តុលាការសួរកូនឈ្មោះ** [redacted] **សុខហេង**

ស.ឆ: ខ្ញុំមានអាយុ៧ឆ្នាំ សព្វថ្ងៃខ្ញុំរស់នៅជាមួយឪពុករបស់ខ្ញុំ។ កាលពីតូចម្តាយរបស់ខ្ញុំធ្លាប់ជូនខ្ញុំទៅរៀន តែពេលនេះឪពុកខ្ញុំជាអ្នកជូនទៅរៀនរហូត។

ស.ឆ: ពេលនេះខ្ញុំចង់រស់នៅជាមួយឪពុករបស់ខ្ញុំៗមិនអាចរស់នៅជាមួយម្តាយខ្ញុំទេ គាត់អាចមកមើលខ្ញុំបាន។

**ចំណុចគ្មានវិវាទ:**

-ដើមចោទទាមទារលែងលះពីចុងចម្លើយ ចុងចម្លើយឯកភាព។

-កូន០១នាក់ឈ្មោះ [redacted] **សុខហេង** កើតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ ដើមចោទ និងចុងចម្លើយ សុំសិទ្ធិអំណាចមេបា។

**ចំណុចវិវាទ: គ្មាន**

II.**ការពិនិត្យភស្តុតាងរបស់គូភាគី:**

-**បានឃើញ** សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។(ថតចម្លង)

-**បានឃើញ** សេចក្តីចម្លងសំបុត្រកំណើតឈ្មោះ [redacted] **សុខហេង** ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣។(ថតចម្លង)



Scanned with CamScanner

## **សំអាងហេតុ**

១.តាមលទ្ធផលសាកសួរ និង ពិនិត្យភស្តុតាងនៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថាៈ ដើមចោទឈ្មោះ [redacted] **គីមហុក** និងចុងចម្លើយឈ្មោះ [redacted] **សម្ផស្ស** បានរៀបអាពាហ៍ពិពាហ៍នឹងគ្នាតាមប្រពៃណី ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ទួលស្វាយព្រៃទី២ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ ត្រឹមត្រូវតាមច្បាប់ ការរស់នៅជាប្តីប្រពន្ធមានភាពមិនចុះសំរុងនិងគ្នា ធ្វើឱ្យដើមចោទនិងចុងចម្លើយអស់មនោសញ្ចេតនា ជាប្តីប្រពន្ធនឹងគ្នាតទៅទៀត។ ដើមចោទសុំឱ្យតុលាការចេញសាលក្រមលែងលះ បណ្តឹងនេះអាចទទួលដោះស្រាយបាន។

២.តុលាការធ្វើការផ្សះផ្សារដល់គូភាគីរួចហើយ តែគូភាគីមិនព្រមសះជានឹងគ្នាវិញទេ គូភាគីជាប្តីប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍និងគ្នា តែការរស់នៅមិនចុះសម្រុងនិងគ្នា មានភាពរកាំរកូស ធ្វើឱ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ដើមចោទនិងចុងចម្លើយ បានឯកភាពលែងលះគ្នាតាមការព្រមព្រៀង គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៣.ដើមចោទ និងចុងចម្លើយអះអាងថា អំឡុងពេលរស់នៅជាមួយគ្នាមានកូន០១នាក់ឈ្មោះ [redacted] **សុខហេង** ភេទស្រី កើតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ តាមសេចក្តីថ្លែងការណ៍ខាងលើ គូភាគីបានទាមទារសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] **សុខហេង** ភេទស្រី កើតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ដូចគ្នា។ តាមចម្លើយកូនឈ្មោះ [redacted] សុខហេង បានឆ្លើយថា ខ្ញុំមានអាយុ៧ឆ្នាំ សព្វថ្ងៃរស់នៅជាមួយឪពុក និងឪពុកជាអ្នកជូនទៅរៀនរហូត ដោយខ្លួនមិនអាចរស់នៅជាមួយម្តាយបានទេ។ តាមរយៈន័យនេះតុលាការពិចារណាសម្រេចតាមច្បាប់ដោយគិតពីផលប្រយោជន៍កូន តាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី។

៤.**អំពីការសួរសុខទុក្ខកូនៈ** ភាគីដែលពុំមានអំណាចមេបាលើកូន ក្រោយពីលែងលះគ្នា មានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូនបាន និង មានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដោយអនុឡោមតាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

៥.**អំពីសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូនៈ**ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ គូភាគីបានទាមទារឱ្យផ្តល់សាហ៊ុយចាំបាច់សម្រាប់ការចិញ្ចឹមកូនតាមលទ្ធភាពរៀងៗខ្លួន ហេតុដូច្នេះតុលាការសម្រេចតាមច្បាប់។

៦.ប្រាក់ប្រដាប់ក្តីតុលាការដើមចោទលោក [redacted] **គីមហុក** ជាអ្នកទទួលបន្ទុក មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

## **សេចក្តីសម្រេចបញ្ចប់**

១.បង្គាប់ឱ្យដើមចោទលោក [redacted] **គីមហុក** និងអ្នកស្រី [redacted] **សម្ផស្ស** លែងលះគ្នាចាប់ពីថ្ងៃនេះតទៅតាមការព្រមព្រៀងរបស់គូភាគី ដោយអនុឡោមតាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី។

២.កំណត់យកលោក [redacted] **គីមហុក** ជាអ្នកមានអំណាចមេបាលើកូន០១នាក់ឈ្មោះ [redacted] **សុខហេង** ភេទស្រី កើតនៅថ្ងៃទី០៣ខែមេសាឆ្នាំ២០១៣ ក្នុងការចិញ្ចឹមគ្រប់គ្រងបីបាច់ថែក្សា តាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ភាគីដែលពុំមានសិទ្ធិអំណាចមេបាមានសិទ្ធិប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត តាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

៣-បង្គាប់ឱ្យភាគីចុងចម្លើយអ្នកស្រី [redacted] សម្ពស្ស ផ្តល់សោហ៊ុយដែលចាំបាច់សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូនរហូតដល់កូនមានវ័យនីតិភាព និងប្រាក់ឧបត្ថម្ភបន្ថែមទៀតតាមលទ្ធភាពដើម្បីឧត្តមប្រយោជន៍ល្អរបស់កុមារ។ លោក [redacted] គឹមហុក ត្រូវបង្កលក្ខណៈងាយស្រួលដល់អ្នកស្រី [redacted] សម្ពស្ស ក្នុងការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៤-ឱ្យអ្នកស្រី [redacted] សម្ពស្ស ស្ថិតនៅភាពមេម៉ាយចំនួន១២០ថ្ងៃ គិតចាប់ពីថ្ងៃនេះ តាមមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី។ ផុតអំឡុងពេលនេះទើបអ្នកស្រី [redacted] សម្ពស្ស អាចរៀបអាពាហ៍ពិពាហ៍បាន។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទនិងចុងចម្លើយ។

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃពុធ១៤កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]